**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល**
**(ខេមបូឌា) ភីអិលស៊ី**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី ២៦ អាណត្តិទី២
## របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ចាប់ពីម៉ោង ៩:០០ ព្រឹក នៅទីស្នាក់ការក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា)ភីអិលស៊ី ដែលមានទីតាំងនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា លោក **Chen Tsung-Chi** នាយកប្រតិបត្តិ និងជាអភិបាលប្រតិបត្តិ នៃក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា)ភីអិលស៊ី ("**ក្រុមហ៊ុន**") បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី២៦ របស់ក្រុមហ៊ុន តាមរយៈប្រព័ន្ធអេឡិចត្រូនិក (Video-Conferens)។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី២៦ អាណត្តិទី២ នេះ អង្គប្រជុំបានពិនិត្យ និងពិភាក្សាយ៉ាងផុសផុលលើខ្លឹមសារលម្អិតនៃរបាយការណ៍ប្រតិបត្តិការរបស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដែលទទួលបានលទ្ធផល និងអនុម័ត ដូច ខាងក្រោម៖

១. លទ្ធផលប្រតិបត្តិការក្រុមហ៊ុនសម្រាប់ត្រីមាសទី១ ឆ្នាំ២០២០ និងសម្រាប់ត្រីមាសបន្ទាប់
២. ការពន្យាពេលផ្តល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រា និងរបាយការណ៍ត្រីមាសទី១ឆ្នាំ២០២០ ជូនគណៈកម្មាការមូលបត្រកម្ពុជា
៣. ការផ្លាស់ប្តូរក្រុមហ៊ុនសវនកម្មឯករាជ្យមុនអាណត្តិ
៤. បញ្ហាផ្សេងៗ

អង្គប្រជុំបានបញ្ចប់ទៅនៅវេលាម៉ោង ១១:០០ ព្រឹក នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ និងឯកភាពគ្នា។

ថ្ងៃពុធ ១១កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០
**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី**